# Kingdom of Cambodia
# Nation Religion King

Ministry of Economic and Finance
General Department of Budget
Number 5995 សហវ / អថ Phnom Penh, 3rd August 2015

**To: Your Excellency Minister of Health**

Subject: The request for using national budget to support officials for outreach activities for activity to provide health services in community.

Ref: Letter number 090 សខណ dated 7 May 2015 of Ministry of Health.

For the above subject and Ref, I would like to inform your Excellency that MoEF have noted and agreed on a principle to provide mission money to health staff for activities of providing health services in communities (outreach activities) which are far from health center and referral hospital within the border of administrative district as following:

- Pocket money 16,000 Riels per one person per day
- Food allowance 16,000 Riels per one person per day
- Travel cost provided in cash according to mean of transportation and distance of travel for mission

This mission money is not provided to health staff for outreach activities in case there is already cash support receiving from other development partners.

The practice of mission money is compliant to Prakas Number 1589 សហវ dated 9 December 2014 about procedure and protocol for in-country and oversea mission for National Administration. The payment requires a specific table reporting about activities of providing health services in community including location, distance from health center and referral hospital within the border of an administrative district.

As above mentioned, your Excellency, for your consideration and effective implementation with highly responsible.

Please accept, Your Excellency, the assurances of my highest consideration.

Minister of Economic and Finance

Stamp and Signature
Doctor Aun Porn Moniroth

CC:
Council Minister
Cabinet of Prime Minister
National Audit
Documentation

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានថវិកា
លេខ [illegible] សហវ/អថ

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ[illegible] ឆ្នាំ២០១៩

គោរពជូន
ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល

**កម្មវត្ថុ**: ការស្នើសុំគោលការណ៍ប្រើប្រាស់ថវិកាជាតិ ដើម្បីឧបត្ថម្ភដល់មន្ត្រីចុះបំពេញការងារនៅតាមមូលដ្ឋាន (Outreach Activities) សម្រាប់សកម្មភាពចុះផ្តល់សេវាសុខភាពដល់សហគមន៍។

**យោង**: លិខិតលេខ០៨០ សនល ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងសុខាភិបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យ និងឯកភាពជាគោលការណ៍ ផ្តល់ប្រាក់បេសកកម្មជូនបុគ្គលិកសុខាភិបាល ចុះបំពេញការងារផ្តល់សេវាសុខាភិបាលនៅតាមមូលដ្ឋាន (Outreach Activities) មានទីតាំងនៅតំបន់ឆ្ងាយពីមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដែលស្ថិតក្នុងរង្វង់ស្រុកប្រតិបត្តិ ដូចខាងក្រោម៖

- ប្រាក់ហោប៉ៅចំនួន ១៦ ០០០ (ដប់ប្រាំមួយពាន់) រៀល សម្រាប់១នាក់/១ថ្ងៃ
- ប្រាក់ហូបចុក ចំនួន ១៦ ០០០ (ដប់ប្រាំមួយពាន់) រៀល សម្រាប់១នាក់/១ថ្ងៃ
- សោហ៊ុយធ្វើដំណើរផ្តល់ជូនជាសាច់ប្រាក់អាស្រ័យលើមធ្យោបាយធ្វើដំណើរ និងចម្ងាយនៃការធ្វើដំណើរក្នុងការបំពេញបេសកកម្ម។

ប្រាក់បេសកកម្មនេះ មិនផ្តល់ជូនបុគ្គលិកសុខាភិបាលដែលចុះបំពេញការងារផ្តល់សេវាសុខាភិបាលនៅតាមមូលដ្ឋានឡើយ ប្រសិនបើមានប្រាក់ឧបត្ថម្ភពីគម្រោងដៃគូអភិវឌ្ឍន៍។

ការអនុវត្តប្រាក់បេសកកម្មត្រូវអនុលោមតាមខ្លឹមសារនៃប្រកាសលេខ១៥៥៩ សហវ.ប្រក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីរបបនិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងប្រទេស និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ។ ការទូទាត់ត្រូវមានតារាងរបាយការណ៍ដោយឡែកសម្រាប់ចុះបំពេញការងារផ្តល់សេវាសុខាភិបាលនៅតាមមូលដ្ឋានមានទីតាំងនៅតំបន់ឆ្ងាយពីមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដែលស្ថិតក្នុងរង្វង់ស្រុកប្រតិបត្តិ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងចាត់ចែងការអនុវត្តប្រកបដោយប្រសិទ្ធភាព និងមានទទួលខុសត្រូវខ្ពស់។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- អង្គភាពសវនកម្មជាតិ
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ: ៨៥៥-២៣-៤៣០ ២២៥ ទូរសារ: ៨៥៥-២៣-៤៣០ ៧៩៩
Tel: 855-23-430 225 / Fax: 855-23-430 799